# តិលោកវិជយចក្កវត្តិរាជគាថា

៤៩. យំ កិញ្ចិ កុសលំ កម្មំ, កត្តព្វំ កិរិយំ មម;
កាយេន វាចា មនសា, តិទសេ សុគតំ កតំ ។

*អំពើជា កុសលណាមួយ ដែលខ្ញុំគប្បីធ្វើដោយកាយ វាចា ចិត្ត (អំពើជាកុសលនោះ) ដែលខ្ញុំបានធ្វើហើយ ជាកុសលគួរដល់ការកើតក្នុងសុគតិ ក្នុងត្រៃត្រិង្ស ។*

៥០. យេ សត្តា សញ្ញិនោ អត្ថិ, យេ ច សត្តា អសញ្ញិនោ;
កតំ បុញ្ញផលំ មយ្ហំ, សព្វេ ភាគី ភវន្តុ តេ ។

*សត្វទាំងឡាយណា មានសញ្ញា និងសត្វទាំងឡាយណា មិនមានសញ្ញា សត្វទាំងអស់នោះ ចូរបាននូវចំណែកផលនៃបុណ្យដែលខ្ញុំបានធ្វើហើយ ។*

៥១. យេសំ កតំ សុវិទិតំ, ទិន្នំ បុញ្ញផលំ មយា;
យេ ច តត្ថ[១៦] ន ជានន្តិ, ទេវា គន្ត្វា និវេទយុំ ។

*សត្វទាំងឡាយណា បានដឹងច្បាស់នូវបុណ្យដែលខ្ញុំបានធ្វើហើយនោះ សត្វទាំងនោះ ( ចូរបានទទួល ) នូវផលនៃបុណ្យដែលខ្ញុំ ឲ្យហើយ ម្យ៉ាងទៀត បណ្ដាសត្វទាំងនោះ សត្វទាំងឡាយណា មិនបានដឹង សូមទេវតាទាំងឡាយអញ្ជើញទៅឲ្យដំណឹង (ដល់សត្វទាំងនោះ) ផង ។*

៥២. សព្វលោកម្ហិ[១៧] យេ សត្តា, ជីវន្តាហារហេតុកា;
មនុញ្ញំ ភោជនំ សព្វំ[១៨], លភន្តុ មម ចេតសា ។

*សត្វទាំងឡាយណាក្នុងលោកទាំងអស់ ដែលអាស្រ័យអាហារហើយរស់នៅ សត្វទាំងអស់នោះ ចូរបាននូវភោជនជាទីគាប់ចិត្ត តាមចិត្តខ្ញុំចុះ ។*

---

[១៦]- តស្មិំ (សី. ក.) ។

[១៧]- សព្វេ លោកម្ហិ (ស្យា. ក.) ។

[១៨]- សព្វេ (ស្យា.) ។

## អធិប្បាយ

៤៩. ឯវំ សោ តិលោកវិជយោ ចក្កវត្តិរាជា បាសាទស្ស ច អត្តនោ ច អានុភាវំ វណ្ណេត្វា ឥទានិ អត្តនា សម្បត្តិកតបុញ្ញផលំ សមាទបេន្តោ "**យំ កិញ្ចិ កុសលំ កម្ម**"ន្តិអាទិមាហ។

*ព្រះបាទតិលោកវិជយចក្កវត្តិរាជ គ្រាសរសើរអានុភាពរបស់ប្រាសាទ និងអានុភាពរបស់ខ្លួនហើយ ឥឡូវនេះ កាលនឹងញុំាងសព្វសត្វឲ្យកាន់យកនូវបុញ្ញផលដែលជាសម្បត្តិដែលព្រះអង្គបានធ្វើហើយ ទើបពោលគាថាជាដើមថា* "**យំ កិញ្ចិ កុសលំ កម្មំ *អំពើជាកុសលណាមួយ***"។

**យំ កិញ្ចិ** កុសលកម្មសង្ខាតំ **កិរិយំ កត្តព្ពំ** អត្ថិ, តំ សព្ពំ **មម** មយា **កាយេន** វា **វាចាយ** វា **មនសា** វា តីហិ ទ្វារេហិ **កតំ តិទសេ សុកតំ** សុដ្ឋុ កតំ, តាវតឹសភវនេ ឧប្បជ្ជនារហំ កតន្តិ អត្ថោ។

*មានសេចក្ដីអធិប្បាយថា ករិយា ពោលគឺ កុសលកម្មយ៉ាងណាមួយ ដែលគប្បីធ្វើ រមែងមាន, កុសលកម្មទាំងអស់នោះ យើងបានធ្វើហើយដោយទ្វារទាំងបី គឺដោយកាយ វាចា ចិត្ត ដែលបានធ្វើល្អហើយ គឺបានធ្វើល្អហើយក្នុងត្រៃទស គឺធ្វើឲ្យជាកុសលគួរដល់ការកើតក្នុងឋានត្រៃត្រិង្ស។*

៥០. បុន សមាទបេន្តោ "**យេ សត្តា សញ្ញិនោ**"តិអាទិមាហ។ តត្ថ **យេ សត្តា** មនុស្សា វា ទេវា វា ព្រហ្មានោ វា **សញ្ញិនោ** សញ្ញាសហិតា **អត្ថិ, យេ ច សត្តា អសញ្ញិនោ** សញ្ញារហិតា អសញ្ញា សត្តា សន្តិ, **តេ សព្ពេ** សត្តា **មយ្ហំ** មយា **កតំ បុញ្ញផលំ, ភាគី ភវន្តុ** បុញ្ញវន្តា ហោន្តូតិ អត្ថោ។

*កាលនឹងញុំាងសព្វសត្វឲ្យកាន់យកនូវបុញ្ញផលម្ដងទៀត ព្រះអង្គទើបពោលពាក្យជាដើមថា* "**យេ សត្តា សញ្ញិនោ *សត្វទាំងឡាយណាមានសញ្ញា***"។ *ក្នុងពាក្យនោះ មានសេចក្ដីអធិប្បាយថា សត្វទាំងឡាយណាជាមនុស្ស ទេវតា ឬព្រហ្ម ដែលជាអ្នកមានសញ្ញា គឺប្រកបដោយសញ្ញា, សត្វទាំងឡាយណាមិនមានសញ្ញា គឺប្រាសចាកសញ្ញា សត្វទាំងអស់*

*នោះ ( ចូរបានទទួល ) នូវផលនៃបុណ្យដែលយើងបានធ្វើហើយ, ចូរជាអ្នកមានចំណែកបុណ្យ គឺចូរជាអ្នកមានបុណ្យ។*

៩១. បុនបិ សមាទបេន្តោ ពោធិសត្តោ "**យេសំ កត**"ន្តិអាទិមាហ។ មយា **កតំ** បុញ្ញំ យេហិ នរនាគគន្ធព្ពទេវេហិ **សុវិទិតំ** ញាតំ, តេសំ **មយា ទិន្នំ បុញ្ញផលំ,** តស្មិំ មយា កតេ បុញ្ញេ ទិន្នភាវំ យេ នរាទយោ **ន ជានន្តិ, ទេវា គន្ត្វា** តេសំ តំ **និវេទយុំ** អារោចយុន្តិ អត្ថោ។

*ព្រះពោធិសត្វកាលនឹងញុំាងសព្វសត្វឲ្យកាន់យកនូវបុញ្ញផលសូម្បីម្តងទៀត ទើបពោលពាក្យជាដើមថា "**យេសំ កតំ សត្វទាំងឡាយណា បានដឹងច្បាស់នូវបុណ្យដែលខ្ញុំបានធ្វើហើយ**"។ មានសេចក្តីអធិប្បាយថា បុណ្យដែលយើងបានធ្វើហើយ ដែលសត្វទាំងឡាយណាមានមនុស្ស នាគ គន្ធព្វ ទេវតា បានដឹងល្អហើយ គឺបានដឹងច្បាស់ហើយ, យើងឲ្យបុញ្ញផលដល់សត្វទាំងឡាយនោះ, សត្វទាំងឡាយណាមានមនុស្សជាដើម មិនដឹងនូវភាពដែលយើងបានធ្វើបុណ្យហើយចែកឲ្យ, សូមទេវតាទាំងឡាយអញ្ជើញទៅឲ្យដំណឹង ដល់សត្វទាំងនោះ ។*

៩២. **សព្ពលោកម្ហិ យេ សត្តា** អាហារនិស្សិតា **ជីវន្តិ,** តេ សព្ពេ សត្តា **មនុញ្ញំ ភោជនំ សព្ពំ មម ចេតសា** មម ចិត្តេន **លភន្តុ,** មម បុញ្ញិទ្ធិយា លភន្តូតិ អត្ថោ។

*សត្វទាំងឡាយណាក្នុងលោកទាំងអស់ ដែលអាស្រ័យអាហារហើយរស់នៅ សត្វទាំងអស់នោះ ចូរបាននូវភោជនជាទីគាប់ចិត្ត តាមចិត្តខ្ញុំ គឺដោយចិត្តរបស់ខ្ញុំ, អធិប្បាយថា ចូរបានដោយបុញ្ញឫទ្ធិរបស់ខ្ញុំ ។*

សុត្តន្តបិដក-អដ្ឋកថា » ខុទ្ទកនិកាយ-អដ្ឋកថា » អបទាន-អដ្ឋកថា **វិសុទ្ធជនវិលាសិនី**» ពុទ្ធវគ្គ» ពុទ្ធាបទាន